អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន
## ការប្រកាសសាលក្រម ក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន នឹងធ្វើឡើងនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) បានប្រកាសថា សាលក្រមនៃសំណុំរឿង០០២/០១ ពាក់ព័ន្ធនឹង នួន ជា និងខៀវ សំផន នឹងត្រូវប្រកាសនៅថ្ងៃព្រហស្បតិ៍ ទី៧ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ០៩:០០ ព្រឹក នៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក។ ប្រសិនបើរកឃើញថា មានពិរុទ្ធភាព នោះសេចក្តីសម្រេចអំពីការផ្តន្ទាទោស និងអំពីការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏នឹងត្រូវប្រកាសនៅក្នុងពេលនោះដែរ។

ជនជាប់ចោទក្នុងសំណុំរឿង០០២/០១ រួមមាននួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន អតីប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ សវនាការលើសំណុំរឿងនេះបានចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ២០១១ និង បានធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនៅខែតុលា ឆ្នាំ២០១៣។ បទចោទប្រកាន់នានាក្នុងសំណុំរឿង០០២/០១ នេះ ផ្តោតលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ និង ការផ្លាស់ទីលំនៅប្រជាជនចេញពីតំបន់ផ្សេងៗទៀត ក្នុងដំណាក់កាលក្រោយទៀត (ដំណាក់កាលទី១ និង ដំណាក់កាលទី២) និង ការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។ អង្គជំនុំជម្រះសាលាដំបូងក៏បានស្តាប់ភស្តុតាងអំពីប្រវត្តិសាវតារ ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិប-តេយ្យ ព្រមទាំងតួនាទីរបស់ជនជាប់ចោទនៅក្នុងរដ្ឋាភិបាលនោះ និង ស្តាប់ភស្តុតាងទាក់ទិននឹងរចនាសម្ព័ន្ធរដ្ឋបាល និង រចនាសម្ព័ន្ធទំនាក់ទំនង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។ ភស្តុតាងទាំងនេះក៏នឹងក្លាយជា មូលដ្ឋានគ្រឹះសម្រាប់ការជំនុំជម្រះក្តីបន្ទាប់ទៀតពាក់ព័ន្ធនឹងជនជាប់ចោទទាំងពីរនេះ នៅក្នុងសំណុំរឿង០០២/០២ ដែលរំពឹងថាអាចនឹងចាប់ផ្តើមនៅចុងឆ្នាំ២០១៤នេះ។

បញ្ហានានាទាក់ទងនឹងការចូលយកព័ត៌មាន សូមទាក់ទងជាមួយមន្ត្រីនាំពាក្យដែលមានរាយនាមដូច ខាងក្រោម

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

នេះ ឬផ្ញើអ៊ីមែលមកកាន់: pas@eccc.gov.kh។ ព័ត៌មានលម្អិតអំពីការចូលយកព័ត៌មាន និង ការចូលរួមរបស់សាធារណជន ក្នុងការប្រកាសសាលក្រមនេះ នឹងផ្តល់ជូននៅសប្តាហ៍ទីមួយនៃខែមិថុនា ឆ្នាំ២០១៤។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh